**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តព្រះសីហនុ**
លេខៈ ១១៤៨/២៣ ល.អ.ជ

ថ្ងៃ ចន្ទ ១២ កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
ខេត្តព្រះសីហនុ ថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ២០២៣

**ជម្រាបជូន**
**លោក Liu Zhengqi អនុប្រធានមន្ទីរពេទ្យសម្ព័ន្ធទីពីរ**
**សាកលវិទ្យាល័យគួយចូវ នៃ TCM នៃសាធារណរដ្ឋប្រជាមានិតចិន**

**កម្មវត្ថុ:** សំណើសូមអញ្ជើញគណៈប្រតិភូមន្ទីរពេទ្យសម្ព័ន្ធទីពីរ សាកលវិទ្យាល័យខេត្តគួយចូវ នៃ TCM បំពេញទស្សនកិច្ចនៅខេត្តព្រះសីហនុ ចាប់ពីថ្ងៃទី២២ ដល់ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៤។

**យោង:** - លិខិតចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣ របស់មន្ទីរការបរទេសខេត្តគួយចូវ នៃសាធារណរដ្ឋប្រជាមានិតចិន។
- ចំណារចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់ឯកឧត្តមអភិបាលស្តីទី នៃគណៈអភិបាលខេត្តព្រះសីហនុ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ រដ្ឋបាលខេត្តព្រះសីហនុសូមជម្រាបជូនលោក **Liu Zhengqi** អនុប្រធានមន្ទីរពេទ្យសម្ព័ន្ធទីពីរ សាកលវិទ្យាល័យខេត្តគួយចូវ នៃ TCM ជ្រាបថា៖ ផ្អែកតាមផែនការកិច្ចសហប្រតិបត្តិការរវាងខេត្តព្រះសីហនុ និងខេត្តគួយចូវ លើវិស័យសុខាភិបាលឆ្នាំ២០២៣ រដ្ឋបាលខេត្តព្រះសីហនុសូមអញ្ជើញលោក **Liu Zhengqi** ដឹកនាំប្រតិភូក្រុមគ្រូពេទ្យជំនាញ មកបំពេញទស្សនកិច្ចនៅខេត្តព្រះសីហនុ ចាប់ពីថ្ងៃទី២២-២៦ ខែមករា ឆ្នាំ២០២៤ ខាងមុខនេះ ដែលសមាសភាពគណៈប្រតិភូ មានរាយនាមដូចខាងក្រោម៖

| | |
|---|---|
| ១- លោក **Liu Zhengqi** | អនុប្រធានមន្ទីរពេទ្យសម្ព័ន្ធទីពីរ សាកលវិទ្យាល័យគួយចូវ នៃ TCM |
| ២- លោក **Gao Yongyue** | នាយករងផ្នែកឱសថ នៃមន្ទីរពេទ្យសម្ព័ន្ធទីពីរ សាកលវិទ្យាល័យខេត្តគួយចូវ នៃ TCM |
| ៣- លោកស្រី **Lan Caihong** | នាយករងផ្នែកចាក់ម្ជុលវិទ្យាសាស្ត្រ និងស្តារនីតិសម្បទា |
| ៤- លោកស្រី **Li Zhilan** | ប្រធានគិលានុបដ្ឋាយិកា ផ្នែកជំងឺថ្លើម |
| ៥- លោកស្រី **Li Xiang** | គ្រូពេទ្យជំនួយ ផ្នែកជំងឺបេះដូង |
| ៦- លោក **Yuan Hong** | អនុប្រធានផ្នែកឱសថ នៃសាខា Qianxinan នៃមន្ទីរពេទ្យសម្ព័ន្ធទីពីរ សាកលវិទ្យាល័យខេត្តគួយចូវ |

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងការិយាល័យទំនាក់ទំនងអន្តរជាតិសាលាខេត្ត តាមរយៈអ៊ីម៉ែល fao.sihanouk@gmail.com ឬទូរស័ព្ទចល័តលេខ: (+855) 99 99 66 98 ។ រាល់ការចំណាយរបស់គណៈប្រតិភូក្នុងអំឡុងពេលបំពេញទស្សនកិច្ចនៅខេត្តព្រះសីហនុ ជាបន្ទុករបស់គណៈប្រតិភូ។

អាស្រ័យដូចនេះ សូម **លោកអនុប្រធាន** ជ្រាប និងដឹកនាំគណៈប្រតិភូមកបំពេញទស្សនកិច្ចនៅខេត្តព្រះសីហនុតាមពេលកាលបរិច្ឆេទខាងលើ តាមការគួរ។

សូម លោក ទទួលនូវសេចក្តីស្រលាញ់រាប់អាន អំពីខ្ញុំ។

**ជ.អភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ**
**អភិបាលរង**

**សៀក ហ៊ីមុលី**

ចម្លងជូន:
- ក្រសួងមហាផ្ទៃ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
  *"ដើម្បីគោរពជូនជ្រាប"*
- ផ្នែកកុងស៊ុលសាធារណរដ្ឋប្រជាមានិតចិន ប្រចាំខេត្តព្រះសីហនុ
  *"ដើម្បីជ្រាប"*
- ឯកសារ កាលប្បវត្តិ